**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ៦៣ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការគាំទ្រដំណើរការសិក្សារបស់សិស្ស សម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ក្នុងអំឡុងពេលឈប់សម្រាកខែធ្នូ ឆ្នាំសិក្សា២០១៩-២០២០ និងត្រៀមបើកបវេសនកាល ឆ្នាំសិក្សា ២០២០-២០២១

ដើម្បីធានាបានគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំដល់សិស្សានុសិស្ស ក្នុងអំឡុងពេលឈប់សម្រាកខែធ្នូ ឆ្នាំ២០២០ និងដើម្បីត្រៀមខ្លួនសម្រាប់ឆ្នាំសិក្សា២០២០-២០២១ ក្រសួងអប់រំ យុវជន និងកីឡា សូមណែនាំ លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈដូចខាងក្រោម៖

## I. ការវាយតម្លៃលទ្ធផលសិក្សា

១. គ្រឹះស្ថានបឋមសិក្សាទាំងអស់មិនតម្រូវឱ្យមានដំណើរការប្រឡងឆមាសទី២ទេ។ លទ្ធផលសិក្សាក្នុងឆមាសទី២ ជាមធ្យមភាគនៃលទ្ធផលប្រចាំខែ កញ្ញា តុលា និងវិច្ឆិកា ដោយបូកបញ្ចូលគ្នា រួចចែកនឹង៣។ មធ្យមភាគប្រចាំឆ្នាំ គឺត្រូវយកមធ្យមភាគប្រចាំឆមាសទី១ បូកនឹងមធ្យមភាគប្រចាំឆមាសទី២ រួចចែកនឹង២។

២. សម្រាប់សិស្សដែលធ្លាក់មធ្យមភាគប្រចាំឆ្នាំ ក្រសួងមិនតម្រូវឱ្យមានការធ្វើតេស្តឡើងថ្នាក់នៅដំណាច់ឆ្នាំសិក្សាទេ ប៉ុន្តែតម្រូវឱ្យមានការជំរុញការសិក្សាបន្ថែមទៀត និងការធ្វើតេស្តឡើងថ្នាក់នៅដើមបវេសនកាលឆ្នាំសិក្សា២០២០-២០២១។

## II. ការគាំទ្រការសិក្សារបស់សិស្ស

១. គ្រប់គ្រឹះស្ថានបឋមសិក្សា ត្រូវបន្តផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការសិក្សាពីចម្ងាយ ឬការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ដល់មាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីជំរុញ និងគាំទ្រសិស្សឱ្យបន្តស្វ័យសិក្សា ឬសិក្សាពីចម្ងាយ តាមបែបប្រពៃណីឱ្យបានជាប់លាប់ នៅតាមផ្ទះ ឬនៅតាមបណ្តុំ។

២. គ្រឹះស្ថានបឋមសិក្សានីមួយៗ ត្រូវបន្តផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រើប្រាស់ថវិកាគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ដើម្បីគាំទ្រមូលនិធិដំណើរការសាលារៀននៅតាមសាលាបឋមសិក្សាសាធារណៈ ដែលបានទទួលថវិកាបើកផ្តល់ជូនកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ និងត្រូវចាត់តាំងអ្នកទទួលខុសត្រូវអនុវត្តសកម្មភាព ដូចខាងក្រោម៖

- ជ្រើសរើសសិស្សក្រីក្រ និងរៀបចំបញ្ជីឈ្មោះសិស្សក្រីក្រផ្លូវការ (ចំពោះគ្រឹះស្ថានបឋមសិក្សាដែលមិនទាន់បានជ្រើសរើស)
- ថតចម្លងសន្លឹកកិច្ចការផ្ទះ និងបែងចែកឱ្យដល់សិស្សក្រីក្រ ទៅតាមមេរៀនដែលមានសិស្សរៀនយឺត និងមេរៀនដែលគ្រូមិនទាន់បានបង្រៀន
- រៀបចំនិងរក្សាទុកឯកសារ សំណើសុំចំណាយថវិកា បង្កាន់ដៃសិស្សទទួលសន្លឹកកិច្ចការផ្ទះ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារគាំទ្រផ្សេងៗ តាមគំរូកិច្ចបញ្ជិកាគណនេយ្យ ដូចបានចែងនៅក្នុងសេចក្ដីណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន (SOF) ឱ្យបានត្រឹមត្រូវ និងតាមពេលវេលាកំណត់។

៣. គណៈគ្រប់គ្រងសាលា គ្រូទទួលបន្ទុកថ្នាក់ ត្រូវជូនដំណឹងទៅដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសិស្សរៀនយឺត ឬ ធ្លាក់មធ្យមភាគ និងសិស្សក្រីក្រ ឱ្យមកសាលារៀនតាមវេន និងពេលវេលា (ឧទាហរណ៍ពេលព្រឹក ថ្នាក់ទី១ ត្រូវមកនៅ ម៉ោង៧:០០នាទី ថ្នាក់ទី២ ម៉ោង៧:៣០នាទី ...) ដើម្បីទទួលឬសន្លឹកកិច្ចការផ្ទះ និងណែនាំពួកគេឱ្យរៀនមេរៀនដែលត្រូវស្វ័យសិក្សានៅផ្ទះ។

៤. ចំពោះគ្រឹះស្ថានបឋមសិក្សាដែលមិនមានលទ្ធភាពបញ្ចប់ការអនុវត្តសកម្មភាពខាងលើ (ចំណុច២) ក្នុងឆ្នាំសិក្សា២០១៩-២០២០ អាចបន្តយកថវិកាទៅអនុវត្តនៅឆ្នាំសិក្សា២០២០-២០២១។

**III. ការពិនិត្យតាមដាន និងរបាយការណ៍**

១. គ្រឹះស្ថានបឋមសិក្សានីមួយៗត្រូវបន្តរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ដើម្បីចូលរួមផ្សព្វផ្សាយ អង្កេត និងអនុវត្តវិធានការការពារ ទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល

២. គ្រូបន្ទុកថ្នាក់នីមួយៗត្រូវបន្តរៀបចំផែនការសម្រាប់ជួយសិស្សដែលធ្លាក់មធ្យមភាគ និងសិស្សរៀនយឺតដទៃទៀត ឱ្យបានរៀនសូត្របន្ថែមក្នុងអំឡុងពេលឈប់សម្រាក់និងត្រៀមបើកបវេសនកាល ២០២០-២០២១ និងដើម្បីត្រៀមធ្វើតេស្តឡើងថ្នាក់នៅដើមឆ្នាំសិក្សាបន្ទាប់ តាមរយៈការផ្តល់ជូននូវសន្លឹកកិច្ចការនៃខ្លឹមសារមេរៀនឆមាសទី២ ដល់សិស្សក្រីក្រ ដែលក្រសួង (នាយកដ្ឋានបឋមសិក្សា) ផ្តល់ជូនតាមរយៈមន្ទីរ អ.យ.ក.រាជធានី ខេត្ត។ គ្រូបន្ទុកថ្នាក់ត្រូវធ្វើរបាយការណ៍តាមដានការសិក្សា របស់សិស្ស ជូនគណៈគ្រប់គ្រងសាលា រៀងរាល់សប្តាហ៍ តាមគំរូរបាយការណ៍ដែលបានណែនាំកន្លងមក។

៣. គណៈគ្រប់គ្រងសាលាត្រូវរៀបចំរបាយការណ៍ប្រចាំខែ ស្តីពីការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងធ្វើរបាយការណ៍បូកសរុបលទ្ធផលសិក្សារបស់សិស្សប្រចាំឆ្នាំ តាមគំរូ របាយការណ៍ដែលបាន ណែនាំកន្លងមក ជូនការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៤. ការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរ អ.យ.ក.រាជធានី ខេត្ត ត្រូវបូកសរុបរបាយការណ៍ប្រចាំខែ ស្តីពីការតាមដានលទ្ធផលសិក្សារបស់សិស្ស (ភ្ជាប់ជាមួយនូវលទ្ធផល តេស្តឡើងថ្នាក់) ជូនក្រសួង (នាយកដ្ឋានបឋមសិក្សា) ត្រឹមសប្តាហ៍ទី២ ខែមករា ឆ្នាំ២០២១។

៥. នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានជំនាញពាក់ព័ន្ធរបស់ក្រសួង នឹងចុះសម្របសម្រួលលើការរៀបចំនិងបូកសរុបរបាយការណ៍ នៅតាមការិយាល័យ អ.យ.ក.នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរ អ.យ.ក .រាជធានី ខេត្ត ទៅតាមតម្រូវការជាក់ស្តែង។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់ ត្រូវចូលរួមអនុវត្ត ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  “ **ដើម្បីជ្រាបជាព័ត៌មាន** ”
- ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា
  “ **ដើម្បីជូនជ្រាប**”
- កាលប្បវត្តិ
- ឯកសារ.នា.បឋមសិក្សា